❋ **មហាវិទ្យាល័យ និងមុខជំនាញ :**

វិទ្យាស្ថានអប់រំកម្ពុជាមានមហាវិទ្យាល័យ ០២ ដែលមានមុខជំនាញ :

**១-មហាវិទ្យាល័យភាសា**

-ជំនាញ : ភាសាអង់គ្លេស

**២-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម**

-ជំនាញ : ទីផ្សារ

-ជំនាញ : ទេសចរណ៍

-ជំនាញ : គណនេយ្យ

-ជំនាញ : គ្រប់គ្រង

## ៣៧-វិទ្យាស្ថានបូលីណូ



❋ **អាសយដ្ឋានទំនាក់ទំនង :**

**-វិទ្យាស្ថានបូលីណូ** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅ ភូមិអូររូង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

-លេខទូរស័ព្ទ : ០២៣ ៨៨ ១៦ ២៣ ០១៧ ២២ ០០០៧

-ទូរសារលេខ: ០២៣ ៨៨ ១៦ ២៣

❋ **មហាវិទ្យាល័យ និងមុខជំនាញ :**

វិទ្យាស្ថានបូលីណូ មានមហាវិទ្យាល័យ ១០ ដែលមានមុខជំនាញ :

**១-មហាវិទ្យាល័យវេជ្ជសាស្ត្រ និងរោគកុមារ**

-ជំនាញ : វេជ្ជសាស្ត្រទូទៅ

-ជំនាញ : រោគកុមារ

**២-មហាវិទ្យាល័យឱសថសាស្ត្រ**

-ជំនាញ :ឱសថសាស្ត្រ

**៣-មហាវិទ្យាល័យទន្តវេទនសាស្ត្រ**

-ជំនាញ : ទន្តសាស្ត្រ

**៤-មហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ**

-ជំនាញ : ស្ថាបត្យកម្ម

-ជំនាញ : សំណង់ស៊ីវិល

-ជំនាញ : ព័ត៌មានសំណង់

-ជំនាញ : អេឡិចត្រូនិច-ទូរគមនាគមន៍

-ជំនាញ : វិស្វកម្មអេឡិចត្រូនិច និងអគ្គិសនី

-ជំនាញ : គណិតវិទ្យាអនុវត្តន៍

-ជំនាញ : បច្ចេកវិទ្យាព័ត៌មាន

-ជំនាញ : បច្ចេកវិទ្យាបរិស្ថាន

-ជំនាញ : វិស្វកម្មបរិស្ថាន

-ជំនាញ : ជីវគីមីសាស្ត្រ

-ជំនាញ : មីក្រូជីវសាស្ត្រ

-ជំនាញ : ជីវបច្ចេកវិទ្យា

-ជំនាញ : ជីវវិទ្យា

-ជំនាញ : គីមីចំណីអាហារ

-ជំនាញ : សុរិយោដី

-ជំនាញ : ព័ត៌មានវិទ្យា និងគ្រប់គ្រង

**៥-មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និង សារព័ត៌មាន**

-ជំនាញ : សង្គមវិទ្យា

-ជំនាញ : វិទ្យាសាស្ត្រនយោបាយ

-ជំនាញ : សារព័ត៌មាន

**៦-មហាវិទ្យាល័យនីតិសាស្ត្រ**

-ជំនាញ : ច្បាប់សាធារណៈ

-ជំនាញ : ច្បាប់ពាណិជ្ជកម្ម

-ជំនាញ : ច្បាប់អន្តរជាតិ

**៧-មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ**

-ជំនាញ : ជលផល

-ជំនាញ : ក្សេត្រសាស្ត្រ

-ជំនាញ : បសុពេទ្យ

**៨-មហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសា**

-ជំនាញ : ភាសាអង់គ្លេស

-ជំនាញ : ភាសាបារាំង

-ជំនាញ : វិទ្យាសាស្ត្រអប់រំ

**៩-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច**

-ជំនាញ : ទីផ្សារ

-ជំនាញ : គ្រប់គ្រង

-ជំនាញ : គណនេយ្យ

-ជំនាញ : គ្រប់គ្រង និងទេសចរណ៍

-ជំនាញ : សេដ្ឋកិច្ច

-ជំនាញ : ហិរញ្ញវត្ថុ និងធនាគារ

**១០-មហាវិទ្យាល័យវិទ្យាសាស្ត្រថែទាំវេជ្ជសាស្ត្រ**

-ជំនាញ : គិលានុបដ្ឋាក

-ជំនាញ : ឆ្មប

-ជំនាញ : វិទ្យុសាស្ត្រ

-ជំនាញ : មន្ទីរពិសោធន៍

-ជំនាញ : ព្យាបាលដោយចលនា

# ៣៨-វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍




❋ **អាសយដ្ឋានទំនាក់ទំនង :**

**-វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលមានទីតាំងនៅ ភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។

-ទូរស័ព្ទលេខ : ០៥២ ៩៥១ ៥១៩

-អ៊ីម៉ែល : mensethy@camintel.com

-គេហទំព័រ : www.imd.edu.kh

❋ **មហាវិទ្យាល័យ និងមុខជំនាញ :**

វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានមហាវិទ្យាល័យ ០៤ ដែលមានមុខជំនាញ :

**១-មហាវិទ្យាល័យគ្រប់គ្រង**

-ជំនាញ : គ្រប់គ្រងទូទៅ

-ជំនាញ : គណនេយ្យ និងហិរញ្ញវត្ថុ

**២-មហាវិទ្យាល័យភាសាបរទេស**

-ជំនាញ : អប់រំភាសាអង់គ្លេស

**៣-មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន**

-ជំនាញ : វិទ្យាសាស្ត្រកុំព្យូទ័រ

**៤-មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច**

-ជំនាញ : ហិរញ្ញវត្ថុ និងធនាគារ

---

# ព័ត៌មានពាក់ព័ន្ធ

# នឹងការសិក្សា

# តាមមុខជំនាញ

## ១.ជំនាញគណិតវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និង រូបវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៤០ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃគណិតវិទ្យា

-យល់ដឹងពីគណិតវិទ្យាអនុវត្តន៍ (ស្ថិតិ តូប៉ូឡូជី..)

-យល់ដឹងពីការវិភាគចំនួន កុំផ្លិច និងចេះភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-សាស្ត្រាចារ្យគណិតវិទ្យា នៅតាមគ្រឹះស្ថានសិក្សា

-តាមបណ្តាក្រសួង ក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។

## ២.ជំនាញរូបវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** រូបវិទ្យា និង គណិតវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៥៣ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃរូបវិទ្យា និងដឹងពីឧបករណ៍អេឡិចត្រូនិច និងសេរ្គី និងថាមពលមេកានិច

-យល់ដឹងពីរូបវិទ្យាបូរាណ រូបវិទ្យាស្ថិតិ រូបវិទ្យាសាគរ រូបវិទ្យាអាតូមិច

-យល់ដឹងពីអេឡិចត្រូឌីណាមិច និងភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ជាសាស្ត្រាចារ្យរូបវិទ្យា នៅតាមគ្រឹះស្ថានសិក្សា

-តាមបណ្តាក្រសួង ក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។

## ៣.ជំនាញគីមីវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គីមីវិទ្យា និង គណិតវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៥៥ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីការពិសោធន៍គីមីវិភាគ គីមីសរីរាង្គ គីមីរូប គីមីជីវៈ គីមីបរិស្ថាន

-យល់ដឹងពីការសំយោគអសរីរាង្គ និងភាសាអង់គ្លេស ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ជាសាស្ត្រាចារ្យគីមី នៅតាមគ្រឹះស្ថានសិក្សា

-ទីពិសោធន៍ផ្សេងៗក្នុងស្ថាប័នរដ្ឋ និងឯកជន (ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

-រោងចក្រផលិតចំណីអាហារ ស៊ីម៉ង់តិ៍ ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ

## ៤.ជំនាញជីវវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ជីវវិទ្យា និងគីមីវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃជីវវិទ្យា

-យល់ដឹងពីសរីរវិទ្យា គីមីជីវៈ កាយវិភាគរុក្ខជាតិ និងសត្វ

-យល់ដឹងពីមីក្រូបវិទ្យា និងយល់ដឹងពីអេកូឡូស៊ីទូទៅ និងភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ជាសាស្ត្រាចារ្យជីវវិទ្យា នៅតាមគ្រឹះស្ថានសិក្សា

-តាមបណ្តាក្រុមហ៊ុន ស្ថាប័ននានា អង្គការក្រៅរដ្ឋាភិបាល និងនៅតាមមន្ទីរពិសោធន៍ផ្សេងៗ ។

**៥-ជំនាញពត៌មានវិទ្យា**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និង រូបវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៦៤ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីការវិភាគ និងធ្វើគំរោងប្រព័ន្ធព័ត៌មានវិទ្យា សរសេរកម្មវិធីកុំព្យូទ័រ

-យល់ដឹងពីការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ទំនាក់ទំនងទិន្នន័យ

-យល់ដឹងពីវិស្វករ Soft Ware កុំព្យូទ័រ Client-Server និងដឹងពីកម្មវិធីសារព័ត៌មាន និងបញ្ញាសិប្បនិម្មិត

-យល់ដឹងពីការគ្រប់គ្រងគំរោង ប្រព័ន្ធប្រតិបត្តិការ និងភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ជាសាស្ត្រាចារ្យកុំព្យូទ័រនៅតាមគ្រឹះស្ថានសិក្សា

-តាមបណ្ដាក្រុមហ៊ុន ធនាគារ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។

**៦-ជំនាញបរិស្ថាន**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ជីវវិទ្យា និង គីមីវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៥៣ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីថាមពល និងបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹង

-យល់ដឹងពីគីមីបរិស្ថាន ច្បាប់បរិស្ថាន អេកូស៊ីសស្ទែម

-យល់ដឹងពីការគ្រប់គ្រងកាកសំណល់បំពុលទឹក និងភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ជាសាស្ត្រាចារ្យផ្នែកជីវវិទ្យា នៅតាមគ្រឹះស្ថានសិក្សា ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។

**៧-ជំនាញគីមីជីវៈ**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គីមីវិទ្យា និងជីវវិទ្យា។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីគីមីសរីរាង្គ គីមីអសរីរាង្គ គីមីជីវៈ គីមីជីវសរីរាង្គ

-យល់ដឹងពីជីវថាមពល ជីវវិទ្យាទូទៅ សារធាតុពុល និងភាសាអង់គ្លេស ។ល។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ**

-ជាសាស្ត្រាចារ្យគីមី នៅតាមគ្រឹះស្ថានសិក្សា

-ទីពិសោធន៍ផ្សេងៗក្នុងស្ថាប័នរដ្ឋ និងឯកជន ( ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )

-រោងចក្រផលិតចំណីអាហារ ស៊ីម៉ង់ត៍ ភេសជ្ជៈ ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។ល។

**៨-ជំនាញវិស្វកម្មនុយក្លេអ៊ែរ**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះ សម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៤០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតទទួលបាន ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីមូលដ្ឋានគ្រឹះនៃគណិតវិទ្យា និងរូបវិទ្យាដើម្បីវិស្វកម្ម

-ចេះវិភាគ និងកំណត់បញ្ហាផ្សេងៗក្នុងធម្មជាតិព្រមទាំងទាញរកមូលហេតុ និងឥទ្ធិពលចេញពីការវិភាគ

-យល់ដឹងពីវិធីសាស្ត្រស្ថិតិនៅក្នុងវិស្វកម្ម និងដឹងពីយន្តការនៃប្រព័ន្ធកំដៅ និងប្រព័ន្ធអង្គធាតុរាវ

-យល់ដឹងពីប្រព័ន្ធថេរភាព និងប្រព័ន្ធរញ្ជួយរបស់ធម្មជាតិ

-បកស្រាយពីដំណោះស្រាយបែបវិស្វកម្មយ៉ាងត្រឹមត្រូវចំពោះប្រព័ន្ធមិនប្រក្រតី

-មានសមត្ថភាពធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងវិស្វករជាច្រើន នៅក្នុងតំបន់ផ្សេងៗ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងក្រសួងដែលមានការពាក់ព័ន្ធ

-សាកលវិទ្យាល័យបាត់ដំបង ក្រុមហ៊ុននៅប្រទេសកូរ៉េ

**៩-ជំនាញទេពកោសល្យ គីមី និងចំណីអាហារ**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៥ ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតទទួលបានក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃរូបធាតុកែច្នៃផលិតផលកសិឧស្សាហកម្ម និងមីក្រូជីវៈអតិសុខុមប្រាណដែលបង្កជំងឺក្នុងចំណីអាហារ

-យល់ដឹងពីស្តង់ដារ និងការវេចខ្ចប់ចំណីអាហារ

-យល់ដឹងពីប្រព្រឹត្តិកម្មនៃការសំអាតទឹក និងផ្នែកកំដៅឧស្សាហកម្ម

-យល់ដឹងពីការគ្រប់គ្រង និងការសិក្សាទីផ្សារ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងវិទ្យាស្ថានប៉ាស្ទ័រ

-ក្រុមហ៊ុន ឬរោងចក្រផលិតភេសជ្ជៈ សុរា និងចំណីអាហារនានា

-ក្រុមហ៊ុនថ្នាំជក់ និងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា

**១០-ជំនាញទេពកោសល្យសំណង់ស៊ីវិល**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៥ ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

-ដឹងពីភាពធន់នៃសម្ភារ ការវិភាគ និងគណនាគ្រឿងបង្គុំ ( អំពីដែក បេតុងអាម៉េ ឈើ បេតុងប្រ៉េកុងត្រាំង)

-យល់ដឹងពីការគណនាគ្រឹះសំណង់

-យល់ដឹងពីការសិក្សា និងគណនា ស្ពាននិងថ្នល់

-ការគ្រប់គ្រងការដ្ឋានសំណង់ និងសំណង់សិល្បៈការណ៍ ។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមហ៊ុនសំណង់នានា

-ក្រុមហ៊ុនផលិតស៊ីម៉ង់ត៍ និងតាមស្ថាប័នផ្សេងៗ ។

**១១-ជំនាញទេពកោសល្យអគ្គិសនី ថាមពល និងទូរគមនាគមន៍**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

-យល់ដឹងពីអគ្គិសនីក្នុងអាគារ និងឧស្សាហកម្ម

-យល់ដឹងពីការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងផ្នែកឧស្សាហកម្ម និងការចែកចាយថាមពលអគ្គិសនី

-ដឹងពីរោងចក្រអគ្គិសនី និងអនុស្ថានីយ៍អគ្គិសនី បណ្តាញអគ្គិសនី

-យល់ដឹងពីស្វ័យប្រវត្តិកម្មទំនើបក្នុងសហគ្រាសឧស្សាហកម្ម

-យល់ដឹងពីប្រព័ន្ធទូរគមនាគមន៍ចល័ត និងអចល័ត ។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-រោងចក្រ ឬក្រុមហ៊ុនអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-ក្រុមហ៊ុនផលិតថ្នាំជក់ ក្រុមហ៊ុនទូរស័ព្ទចល័ត និងអចល័ត អង្គការ និងតាមស្ថាប័នផ្សេងៗ ។

**១២-ជំនាញទេពកោសល្យព័ត៌មានវិទ្យា និងទំនាក់ទំនង**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

-យល់ដឹងពីវិធីសាស្ត្រក្នុងការសរសេរកម្មវិធីកុំព្យូទ័រ

-យល់ដឹងពីប្រពន្ធ័ប្រតិបត្តិការម៉ាស៊ីនកុំព្យូទ័រ

-យល់ដឹងពីប្រពន្ធ័គ្រប់គ្រងទិន្នន័យ បណ្តាញកុំព្យូទ័រ តក្កវិទ្យា

-យល់ដឹងពីកម្មវិធី Intenet និងកម្មវិធីពហុព័ត៌មាន និងបញ្ញាសិប្បនិម្មិត ។

- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យតាមគ្រឹះស្ថានសិក្សា
  - ក្រុមហ៊ុនទូរស័ព្ទចល័ត និងអចល័ត ក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ ។

**១៣-ជំនាញវិស្វករអគ្គិសនីឧស្សាហកម្ម និងមេកានិច**

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**
  - យល់ដឹងពីមេកានិកនៃអង្គធាតុរឹង និងអង្គធាតុរាវ ទែរម៉ិក និងទែរម៉ូឌីណាម៉ិក
  - យល់ដឹងពីវិទ្យាសាស្ត្រ និងភាពធន់នៃសម្ភារៈ
  - យល់ដឹងពីការឆ្នៃសម្ភារៈ ផលិតកម្មមេកានិក មាត្រាសាស្ត្រ
  - យល់ដឹងពីសិក្សាគម្រោង និងប្លង់ម៉ូទ័រចំហេះក្នុង
  - យល់ដឹងពីម៉ាស៊ីនបរិក្ខារត្រជាក់ស្វ័យប្រវត្តិកម្ម អេឡិចត្រូតិចនិក
  - យល់ដឹងពីការរៀបចំ និងការគ្រប់គ្រងសហគ្រាស ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រុមហ៊ុនផលិតថ្នាំជក់
  - តាមបណ្តាក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ ។

**១៤-ជំនាញវិស្វករអគ្គិសនីជនបទ (វិស្វកម្មធនធានទឹក និងភូគព្ភសាស្ត្រ)**

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៥ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំ :**

  **ក. វិស្វកម្មធនធានទឹកៈ**
  - យល់ដឹងអំពីវារីអគ្គិសនី
  - យល់ដឹងពីសំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសំណង់ធារាសាស្ត្រ
  - យល់ដឹងពីការវិភាគគុណភាពទឹក ប្រពន្ធ័ទឹកស្អាត និងការរំដោះទឹកកខ្វក់ ។

  **ខ. វិស្វកម្មភូគព្ភសាស្ត្រៈ**
  - យល់ដឹងពីឋានលេខា និងព័ត៌មានភូមិសាស្ត្រ
  - យល់ដឹងពីគ្រឹះសំណង់អគារ និងផ្លូវថ្នល់
  - យល់ដឹងពីអាជីវកម្មខ្សាច់ ដីឥដ្ឋ គ្រួស និងអាជីវកម្មស៊ីម៉ង់ត៍ ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ
  - អាជ្ញាធរពាក់ព័ន្ធនានា មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍វិស័យកសិកម្ម ក្រុមហ៊ុន អង្គការ និងតាមស្ថាប័នផ្សេងៗ ។

**១៥-ជំនាញអក្សរសាស្ត្រខ្មែរ**

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងប្រវត្តិវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៦៥ ក្រេឌីត ។
- **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - មូលដ្ឋានគ្រឹះនៃអក្សរសាស្ត្រខ្មែរ និងអក្សរសិល្ប៍ខ្មែរ អាស៊ី បស្ចិម ចិន និងឥណ្ឌា
  - យល់ដឹងពីទ្រឹស្តីអក្សរសិល្ប៍ វប្បធម៌ វេយ្យាករណ៍ ភាសាវិទ្យា វិធីសាស្ត្រស្រាវជ្រាវ
  - យល់ដឹងពីបាលីសំស្ក្រឹត សិល្បៈវិទ្យា សិលាចារឹក និងភាសាអង់គ្លេស ។ល។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៅតាមគ្រឹះស្ថានសិក្សា
  - ជំនាញវិជ្ជានិពន្ធ ជំនាញមគ្គុទេសក៍ទេសចរណ៍ ការងាររដ្ឋបាល តាមអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ។

**១៦-ជំនាញឧស្សាហវិជ្ជា**

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងពលរដ្ឋវិជ្ជា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៦៤ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា និងដឹងពីទស្សនវិជ្ជាប្រវត្តិសាស្ត្រ សាសនា និងទស្សនវិជ្ជាវិទ្យាសាស្ត្រសង្គម

-យល់ដឹងពីប្រវត្តិគំនិតនយោបាយកម្ពុជា តក្កវិជ្ជា មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនយោបាយ

-យល់ដឹងពីរូបធាតុនិយម បដិសំយោគ ផែនការយុទ្ធសាស្ត្រ និងភាសាអង់គ្លេស ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-សាស្ត្រាចារ្យទស្សនវិជ្ជា នៅតាមគ្រឹះស្ថានសិក្សា

-ការងាររដ្ឋបាល តាមក្រសួង ក្រុមហ៊ុន តាមបណ្តាអង្គការ ស្ថាប័នផ្សេងៗ ។

**១៧_ជំនាញប្រវត្តិវិទ្យា**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៤៨ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃប្រវត្តិវិទ្យា និងដឹងពីប្រវត្តិស្រាវជ្រាវនិពន្ធ ប្រវត្តិសាស្ត្រសកលលោក

-យល់ដឹងពីសិលាចារិកមុនអង្គរ និងសម័យអង្គរ ប្រវត្តិសិល្បៈខ្មែរ

-យល់ដឹងពីមគ្គទេសក៍ទេសចរណ៍ ប្រវត្តិឧស្សាហកម្មទេសចរណ៍ និងភាសាអង់គ្លេស ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-សាស្ត្រាចារ្យប្រវត្តិវិទ្យា នៅតាមគ្រឹះស្ថានសិក្សា

-ការងាររដ្ឋបាល តាមក្រសួង តាមបណ្តាអង្គការ ស្ថាប័នផ្សេងៗ ការងារក្រុមហ៊ុននានា។

**១៨_ជំនាញភូមិវិទ្យា និងរៀបចំដែនដី**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភូមិវិទ្យា និងគណិតវិទ្យា។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៦០ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃភូមិវិទ្យា និងដឹងពីភូមិវិទ្យារូបកម្ពុជា ឧស្សាហកម្ម ផែនដីវិទ្យា ភូមិវិទ្យានយោបាយ

-យល់ដឹងពីការដឹកជញ្ជូនអន្តរជាតិ ការរៀបចំដែនដី

-យល់ដឹងពីកំណើនប្រជាជន និងការអភិវឌ្ឍន៍ និងភាសាអង់គ្លេស ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-សាស្ត្រាចារ្យភូមិវិទ្យា សាស្ត្រាចារ្យផែនដីវិទ្យា សាស្ត្រាចារ្យបរិស្ថាន នៅតាមគ្រឹះស្ថានសិក្សា

-ក្រសួងបរិស្ថាន ការងារក្រុមហ៊ុននានា និងជាអ្នកសិក្សាស្រាវជ្រាវជាមួយអង្គការក្រៅរដ្ឋាភិបាល។

**១៩_ជំនាញចិត្តវិទ្យា**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងជីវវិទ្យា។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៦៣ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃចិត្តវិទ្យា និងយល់ដឹងពីចិត្តវិទ្យាអន្តរវប្បធម៌ ការព្យាបាលលក្ខណៈគ្រួសារ

-យល់ដឹងពីទ្រឹស្តីបុគ្គលិកលក្ខណៈ នរៈចិត្តវិទ្យា ចិត្តវិទ្យាអប់រំ

- យល់ដឹងពីវិធីសាស្ត្រស្រាវជ្រាវនិងស្ថិតិក្នុងចិត្តវិទ្យា និងភាសាអង់គ្លេស ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-សាស្ត្រាចារ្យចិត្តវិទ្យា នៅតាមគ្រឹះស្ថានសិក្សា និងជាអ្នកជំនាញជាអ្នកស្រាវជ្រាវរបស់ក្រុមហ៊ុន

-បណ្តាអង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុន និងស្ថាប័នផ្សេងៗ ។

**២០_ជំនាញសង្គមវិទ្យា**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងគណិតវិទ្យា។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៥៨ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-យល់ដឹងពីវិទ្យាសាស្ត្រនយោបាយ ស្រាវជ្រាវវិភាគទិន្នន័យសង្គមវិទ្យា

-យល់ដឹងពីសង្គមវិទ្យាវប្បធម៌ សាសនា បរិស្ថាន សេដ្ឋកិច្ច

-យល់ដឹងពីការស្រាវជ្រាវ និងនិពន្ធក្នុងសង្គមវិទ្យា និងភាសាអង់គ្លេស ។ល។

- ◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - -សាស្ត្រាចារ្យសង្គមវិទ្យា នៅតាមគ្រឹះស្ថានសិក្សា
  - -តាមបណ្តាអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុន និងស្ថាប័ននានា។

**២១.ជំនាញសង្គមកិច្ចវិទ្យា**

- ◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាខ្មែរ និងគណិតវិទ្យា។
- ◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៦០ ក្រេឌីត ។
- ◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - -យល់ដឹងពីប្រវត្តិគំនិតនយោបាយ អភិវឌ្ឍន៏គម្រោង
  - -យល់ដឹងពីសង្គមវិទ្យាសាសនា សង្គមវិទ្យាច្បាប់ និងសង្គមវិទ្យាប្រជាធិបតេយ្យ
  - -យល់ដឹងពីសង្គមវិទ្យាទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ និងភាសាអង់គ្លេស ។ល។
- ◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ**
  - -សាស្ត្រាចារ្យសង្គមវិទ្យា នៅតាមគ្រឹះស្ថានឧត្តមសិក្សា
  - -តាមបណ្តាអង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុន និងស្ថាប័ននានា ។

**២២.ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍**

- ◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ភាសាអង់គ្លេស និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីភាសាអង់គ្លេស និងវប្បធម៌ទូទៅ ។
- ◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។
- ◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - -យល់ដឹងពីភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងមូលដ្ឋានសារព័ត៌មាន
  - -យល់ដឹងពីច្បាប់ និងសីលធម៌ប្រព័ន្ធផ្សព្វផ្សាយ
  - -យល់ដឹងពីការស្រាវជ្រាវ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ
  - -យល់ដឹងពីទំនាក់ទំនងសាធារណៈ និងពាណិជ្ជកម្ម
- ◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - -ស្ថាប័នរដ្ឋ (ក្រសួងព័ត៌មាន ស្ថានីយទូរទស្សន៍)
  - -អ្នកយកព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស និងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល។

**២៣.ជំនាញគ្រប់គ្រង**

- ◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសំរាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងពលរដ្ឋវិទ្យា ។
- ◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត ។
- ◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - -យល់ដឹងពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង
  - -ចេះធ្វើផែនការយុទ្ធសាស្ត្រ និងគ្រប់គ្រងធនធានមនុស្ស ។
- ◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - -គ្រប់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋាភិបាលជាតិ/អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល
  - -អង្គភាពអាជីវកម្មផ្ទាល់ខ្លួន និងឯកជន ។

**២៤.ជំនាញម៉ាឃីតធីង**

- ◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសំរាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងពលរដ្ឋវិទ្យា ។
- ◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត ។
- ◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**
  - -យល់ដឹងពីមូលដ្ឋានគ្រឹះនៃទីផ្សារ និងការស្រាវជ្រាវទីផ្សារ
  - -យល់ដឹងពីការគ្រប់គ្រងទីផ្សារ និងរៀបចំផែនការយុទ្ធសាស្ត្រ
  - -យល់ដឹងពីយុទ្ធសាស្ត្រនៃការកំណត់ថ្លៃ
- ◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**
  - -គ្រប់ស្ថាប័នរដ្ឋ ភ្នាក់ងាររដ្ឋាភិបាលជាតិ/អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល
  - -អង្គភាពអាជីវកម្មផ្ទាល់ខ្លួន និងឯកជន ។

**២៥-ជំនាញទេសចរណ៍**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភូមិវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល៤ ឆ្នាំ ស្មើនឹង ១២៩ ក្រេឌិត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីសេដ្ឋកិច្ចទេសចរណ៍ជាតិ និងអន្តរជាតិ

-យល់ដឹងពីការបង្កើន និងវិភាគសក្តានុពលទេសចរណ៍

-យល់ដឹងពីជំនាញក្នុងផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ច និងដឹងពីវិធីជាមគ្គុទេសក៍ទេសចរណ៍ដ៏ចំណាន ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សារៀនចប់មុខជំនាញនេះអាចទៅបម្រើការងារបាន:**

-នៅតាមក្រសួង និងមន្ទីរទេសចរណ៍ តាមសណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍

-បើកក្រុមហ៊ុនទេសចរណ៍ដោយខ្លួនឯង

**២៦-ជំនាញសេដ្ឋកិច្ច-ពាណិជ្ជកម្ម**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់សិក្សាមុខជំនាញនេះ:** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើជំនាញនេះ :**មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១២៩ ក្រេឌិត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ ឆ្នាំ :**

-ចំណេះដឹងទូទៅពីទ្រឹស្តីសេដ្ឋកិច្ច

-យល់ដឹងពីគោលនយោបាយរដ្ឋាភិបាលលើបញ្ហាសេដ្ឋកិច្ច ពាណិជ្ជកម្មអន្តរជាតិ និងអត្ថប្រយោជន៍

-ចំណេះដឹងមូលដ្ឋានរបស់អាជីវកម្ម កិច្ចការគណនេយ្យ និងធនាគារ

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សារៀនចប់មុខជំនាញនេះអាចទៅបម្រើការងារបាន :**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាស្ត្រាចារ្យនៅតាមគ្រឹះស្ថានសិក្សា

-អ្នកកត់ត្រាបញ្ជីរបស់ក្រុមហ៊ុនឯកជននានា ជាអ្នកវិភាគសេដ្ឋកិច្ច វិភាគគម្រោង

-អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិនានា ។ល។

**២៧-ជំនាញនីតិសាស្ត្រ**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់សិក្សាមុខជំនាញនេះ :**ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :**មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១៤៦.៥ ក្រេឌិត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីច្បាប់

-យល់ដឹងពីទ្រឹស្តីច្បាប់ជាមូលដ្ឋាន ទ្រឹស្តីជំនាញ

-យល់ដឹងពីការងារប្រតិបត្តិ និងសីលធម៌ និងអាចពិគ្រោះយោបល់ផ្នែកច្បាប់ ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-គ្រប់ក្រសួងជំនាញ ស្ថាប័នតុលាការ ( ចៅក្រម មេធាវី ក្រឡាបញ្ជី សាការី )

-ក្រុមហ៊ុនមេធាវីឯកជន អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិនានា ក្រុមហ៊ុនឯកជនជាតិ និងអន្តរជាតិ ។

**២៨-ជំនាញរដ្ឋបាលសាធារណៈ**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសំរាប់ទៅសិក្សាមុខជំនាញនេះ :**ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :**មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១៣៧ ក្រេឌិត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ** :

-ចំណេះដឹងពីទ្រឹស្តីជាមូលដ្ឋាន ទ្រឹស្តីឯកទេសខាងច្បាប់នយោបាយ និងសីលធម៌

-ចំណេះដឹងពីការពិគ្រោះយោបល់ផ្នែកច្បាប់ ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-គ្រប់ស្ថាប័នរដ្ឋបាលសាធារណៈ និងគ្រប់ក្រសួងជំនាញ

-ស្ថាប័នតុលាការ ( ចៅក្រម មេធាវី ក្រឡាបញ្ជី សាការី ) ក្រុមហ៊ុនមេធាវីឯកជន និងអន្តរជាតិ

-អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិនានា ក្រុមហ៊ុនឯកជនជាតិ និងអន្តរជាតិ ។

**២៩-ជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១៣១ ក្រេឌិត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីទ្រឹស្តីសេដ្ឋកិច្ច និងការគ្រប់គ្រង

-យល់ដឹងពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការព្យាករណ៍សេដ្ឋកិច្ច ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ

-ធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជននានា ។

## ៣០-ជំនាញធនាគារ និងហិរញ្ញវត្ថុ

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១២៩ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីទ្រឹស្តីធនាគារ និងហិរញ្ញវត្ថុ

-ដឹងពីផ្នែកធនាគារ និងហិរញ្ញវត្ថុ និងយល់ដឹងពីហានិភ័យធនាគារ និងហិរញ្ញវត្ថុ

-យល់ដឹងពីស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិ ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាក់ព័ន្ធ ធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ

-អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជននានា ទីផ្សារហ៊ុន ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលបត្រ ។

## ៣១-ជំនាញគណនេយ្យ

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសំរាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១៣២ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីទ្រឹស្តីគណនេយ្យ និងហិរញ្ញវត្ថុ

-យល់ដឹងពីការងារពន្ធដារ សវនកម្ម និងការងារពាក់ព័ន្ធ

-យល់ដឹងពីការគ្រប់គ្រងទីផ្សារហិរញ្ញវត្ថុ និងស្តង់ដារគណនេយ្យ ការវិភាគ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

◆**អង្គភាព ឬ មូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ:**

-ក្រសួងពាក់ព័ន្ធ ( ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ) នៅធនាគារជាតិ និងធនាគារឯកជន

-ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការ ក្រុមហ៊ុនសវនកម្ម និងក្រុមហ៊ុនផ្តល់សេវាកម្មគណនេយ្យ និងក្រុមហ៊ុននានា។

## ៣២-ជំនាញសេដ្ឋកិច្ចព័ត៌មានវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ ឆ្នាំ ស្មើនឹង ១៣៧ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ ឆ្នាំ :**

-ចំណេះដឹងទូទៅអំពីទ្រឹស្តីវិទ្យាសាស្ត្រកុំព្យូទ័រ និងសេដ្ឋកិច្ច

-ចេះប្រើប្រាស់ និងអនុវត្តជាក់ស្តែងផ្នែកបច្ចេកវិទ្យាកុំព្យូទ័រ ។

◆**អង្គភាព ឬ មូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ:**

-ក្រសួងពាក់ព័ន្ធ នៅធនាគារជាតិ និងធនាគារឯកជន ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការ និងក្រុមហ៊ុនឯកជននានា ។

## ៣៣-ជំនាញបុរាណវិទ្យា

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពីប្រវត្តិប្រាសាទ និងបុរាណដ្ឋាននៅកម្ពុជា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៤៤ ក្រេឌីត ។

◆**ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះនៃវប្បធម៌ អារ្យធម៌ ជំនឿទំនៀមទំលាប់ខ្មែរ អាស៊ីអាគ្នេយ៍ និងអារ្យធម៌ធំៗក្នុងលោក

-យល់ដឹងពីឯកទេសបុរាណវិទូ នរវិទូ ឯកទេសផ្នែកជួសជុល និងថែទាំបេតិកភណ្ឌ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រសួងមន្ទីរ ស្ថាប័នរដ្ឋ និងអាជ្ញាធរជាតិដែលពាក់ព័ន្ធផ្នែកវប្បធម៌ ( អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ)

-អង្គការអន្តរជាតិ ដែលកំពុងប្រតិបត្តិជួសជុលប្រាសាទ និងស្រាវជ្រាវអំពីសង្គម-វប្បធម៌។

## ៣៤-ជំនាញស្ថាបត្យកម្ម និងនគរូបនីយវិទ្យា

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** រូបវិទ្យា និងគណិតវិទ្យា និងត្រូវឆ្លងកាត់ការប្រឡងអំពីគំនូរមើលឃើញ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៥ឆ្នាំកន្លះ ស្មើនឹង ១៤៤ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានចំណេះដឹងអំពីការថែទាំអភិរក្សស្ថាបត្យកម្មបុរាណ

-យល់ដឹងពីការសិក្សាគម្រោងស្ថាបត្យកម្ម និងសាងសង់

-យល់ដឹងពីការបង្កើតផែនការមេ សម្រាប់ការរៀបចំក្រុង និងរៀបចំដែនដី ។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-តាមស្ថាប័នរដ្ឋ និងឯកជន អង្គការនានា ការងារជួសជុលនិងថែទាំប្រាសាទបុរាណនានា

-ក្លាយជាស្ថាបត្យករ និងអ្នកម៉ៅការសាងសង់ តាមរយៈការបើកក្រុមហ៊ុនសាងសង់ផ្ទាល់ខ្លួន ។

## ៣៥-ជំនាញតុបតែងលំអនៃស្ថាបត្យកម្ម

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពី គំនូរមើលឃើញ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-មូលដ្ឋានគ្រឹះអំពីរបៀបតុបតែងលំអខាងក្នុង និងខាងក្រៅគេហដ្ឋាន ឬអគារគ្រប់ប្រភេទ

-ដឹងពីក្បាច់ និងសោភណ្ឌភាព អំពីស្ថាបត្យកម្មខ្មែរ និងចេះបកស្រាយអត្ថន័យនៃតម្លៃសិល្បៈខ្មែរ

-ស្គាល់ពីតម្លៃសិល្បៈបែបប្រពៃណីបុរាណ និងតាមបែបសម័យទំនើប

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-ក្រុមហ៊ុនសំណង់ ឬក្រុមហ៊ុនតុបតែង និងអាចមានលទ្ធភាពប្រកបអាជីវកម្មផ្ទាល់ខ្លួន ។

## ៣៦-ជំនាញគំនូរវិចិត្រកម្ម

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពី គំនូរមើលឃើញ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ស្គាល់ទីតាំងបុរាណដ្ឋានប្រវត្តិសាស្ត្រ ដើម្បីសិក្សាពីមូលដ្ឋានក្បាច់ និងសោភ័ណភាពស្ថាបត្យកម្មខ្មែរ

-ចេះថតរូប និងរោងជាងឯកទេសនីមួយៗ និងដឹងពីប្រវត្តិសិល្បៈខ្មែរ សិល្បៈអាស៊ីអាគ្នេយ៍ និងបស្ចិមប្រទេស

-ចេះរៀបចំពណ៌ ក្បាច់ខ្មែរ គំនូរទេសភាព សោភ័ណវិទ្យា ។ល។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-តាមស្ថាប័នរដ្ឋ ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិក និងតុបតែង

-តាមសារមន្ទីរ និងស្ថាប័នដែលថែរក្សាគំនូរបុរាណដែលមានតម្លៃប្រវត្តិសាស្ត្រ និងអាចបើកអាជីវកម្មផ្ទាល់ខ្លួន ។

## ៣៧-ជំនាញចម្លាក់ទំនើប

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពី គំនូរមើលឃើញ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ដឹងមូលដ្ឋានគ្រឹះនៃក្បាច់ និងសោភ័ណភាពសស្ថាបត្យកម្មខ្មែរ

-ដឹងពីក្បួនខ្នាតខ្មែរ និងនិន្នាការសិល្បៈសហសម័យ និងសិល្បៈដែលឆ្លុះបញ្ចាំងតាមគំនិត

-ចេះប្រៀបធៀបប្រវត្តិសិល្បៈខ្មែរ និងសិល្បៈបស្ចិមប្រទេស និងចេះបកស្រាយពីតម្លៃនៃសិល្បៈខ្មែរ ។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-តាមស្ថាប័នរដ្ឋ ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិក និងតុបតែង

-តាមសារមន្ទីរ និងស្ថាប័នដែលធ្វើការថែរក្សាប្រាសាទ និងរូបចម្លាក់

-ក្លាយជាសិល្បៈករចម្លាក់ និងអាចបើកអាជីវកម្មផ្ទាល់ខ្លួន ។

**៣៨-ជំនាញគំនូរសារគមនាគមន៍**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ប្រវត្តិវិទ្យា និងភាសាខ្មែរ និងត្រូវឆ្លងកាត់ការប្រឡងអំពី គំនូរមើលឃើញ ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៥០ ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងពីរបៀបឆ្នៃបង្កើតគំរូផលិតផល  ការវេចខ្ចប់ទំនិញ  រូបភាពឡូហ្គោ

-ដឹងពីក្បូនខ្នាតខ្មែរ និងនិន្នាការសិល្បៈសហសម័យ និងសិល្បៈដែលឆ្លុះបញ្ចាំងតាមគំនិត

-ដឹងមូលដ្ឋានគ្រឹះនៃក្បាច់ និងសោភ័ណភាពស្ថាបត្យកម្មខ្មែរ និងចេះបកស្រាយពីតម្លៃនៃសិល្បៈខ្មែរ ។

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-តាមស្ថាប័នរដ្ឋ ឬក្រុមហ៊ុន ដែលធ្វើការពាក់ព័ន្ធក្រាហ្វិកឌីហ្សាញ និងតុបតែង

-តាមបណ្ដាគ្រឹះស្ថានបោះពុម្ពផ្សាយ និងរោងពុម្ព អាចមានលទ្ធភាពប្រកបអាជីវកម្មផ្ទាល់ខ្លួន ។

**៣៩-ជំនាញគ្រប់គ្រងធនធានមនុស្ស**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** ពលរដ្ឋវិជ្ជា និងគណិតវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ យ៉ាងតិច ១២០ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងក្នុងការគ្រប់គ្រងមនុស្សនៅក្នុងអង្គភាព  និងការរៀបចំផែនការយុទ្ធសាស្ត្រ

-ដឹងពីការធ្វើផែនការបណ្ដុះបណ្ដាលបុគ្គលិក និងរៀបចំធនធានមនុស្ស

-យល់ដឹងពីការវាយតម្លៃគុណភាពបុគ្គលិក ទំនាក់ទំនងក្នុងអង្គភាព និងបណ្ដាក្រុមហ៊ុននានា

-ចេះពីរៀបចំលក្ខខណ្ឌការងារ សុវត្ថិភាពការងារ និងសុកមាលភាពការងារ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះអាចទៅបម្រើការងារ :**

-គ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុននានា អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិនានា ។

**៤០-ជំនាញពាណិជ្ជកម្មអន្តរជាតិ**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះ សម្រាប់ទៅសិក្សាមុខជំនាញនេះគឺ** : ភាសាខ្មែរ និងគណិតវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១២០ក្រេឌីត ។

◆ **ចំណេះដឹងដែលនិស្សិតទទួលបានក្រោយពីបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងមូលដ្ឋាននៃការគ្រប់គ្រងពាណិជ្ជកម្ម និងពាណិជ្ជកម្មអន្តរជាតិ

-ចំណេះដឹងអំពីបរិស្ថានពាណិជ្ជកម្មអន្តរជាតិ និងភាពជាអ្នកដឹកនាំ

-យល់ដឹងពីក្រមសីលធម៌នៃការធ្វើជំនួញប្រកបដោយភាពជោគជ័យ

-យល់ដឹងពីវិធីសាស្ត្រនៃការកាត់បន្ថយហានិភ័យក្នុងការធ្វើពាណិជ្ជកម្ម ។

◆ **នៅពេលដែលបញ្ចប់ការសិក្សាមុខជំនាញនេះនិស្សិតអាចទៅបម្រើការងារ :**

-ក្រសួងស្ថាប័ននានា ( ក្រសួងពាណិជ្ជកម្ម ) ក្រុមហ៊ុននីហរ័ណ អាហរ័ណ និងតាមអង្គការជាតិ និងអន្តរជាតិ

-ការងារផ្នែកអភិវឌ្ឍន៍ជំនួញ និងអាចបើកអាជីវកម្មដោយខ្លួនឯង ។

**៤១-ជំនាញគ្រប់គ្រងសណ្ឋាគារ**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះ សម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** គណិតវិទ្យា និងសីលធម៌ពលរដ្ឋ ។

◆ **ដើម្បីសិក្សាអោយទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ៤ឆ្នាំ ស្មើនឹង ១៣២ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ឆ្នាំ :**

-ចំណេះដឹងទូទៅផ្នែកគ្រប់គ្រងសណ្ឋាគារ និងការគ្រប់គ្រង និងបណ្ដុះបណ្ដាលបុគ្គលិក

-ចំណេះដឹងផ្នែកជំនាញវិភាគ និងព្យាករណ៍ស្ថានភាពសង្គម និងសេដ្ឋកិច្ច ។

◆ **ក្រោយពេលបញ្ចប់ការសិក្សាលើមុខជំនាញនេះ និស្សិតអាចទៅបម្រើការងារបាននៅ :**

-តាមស្ថាប័នរដ្ឋ និងស្ថាប័នឯកជន  សណ្ឋាគារ  ភោជនីយដ្ឋាន និងក្រុមហ៊ុននានា

-ក្លាយជាម្ចាស់ជំនួញខ្លួនឯងបាន ។

**៤២-ជំនាញភាសាអង់គ្លេស**

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាមុខជំនាញនេះ :** សីលធម៌ពលរដ្ឋ  និងភាសាអង់គ្លេស និងត្រូវឆ្លងកាត់ការប្រឡងវិញ្ញាសាសរសេរភាសាអង់គ្លេស ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ យ៉ាងតិច ១២០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតទទួលបានក្រោយបញ្ចប់ការសិក្សារយៈពេល ៤ឆ្នាំ :**

-ចំណេះដឹងជំនាញ ការសរសេរ ស្តាប់ អាន និងនិយាយ

-ចំណេះដឹងទូទៅផ្នែកភាសា និងជំនាញបកប្រែភាសា និងជំនាញជាមគ្គុទ្ទេសក៍ទេសចរណ៍ ។

◆ **អង្គភាព ឬ មូលដ្ឋានដែលនិស្សិតសិក្សាចប់អាចទៅបម្រើការងារ :**

-គ្រប់ក្រសួងស្ថាប័ន ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិ

-សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងក្លាយជាមគ្គុទ្ទេសក៍ទេសចរណ៍ដ៏ចំណាន ។

## ៤៣-ជំនាញភាសាកូរ៉េ

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** សីលធម៌ពលរដ្ឋ និងត្រូវឆ្លងកាត់ការប្រឡងភាសាខ្មែរ និងភាសាអង់គ្លេស ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៣០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋាន ដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងពីជំនាញប្រាស្រ័យទាក់ទងទាំងបួនគឺ សរសេរ អាន ស្តាប់ និងនិយាយ

-ចេះសរសេរគម្រោងស្រាវជ្រាវ និងចំណេះដឹងខាងវប្បធម៌ និងអក្សរសាស្ត្រកូរ៉េ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-តាមក្រសួង និងស្ថានប័នដែលពាក់ព័ន្ធ (ក្រសួងទេសចរណ៍)

-ស្ថានទូតកូរ៉េ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលមកពីប្រទេសកូរ៉េ

-ក្លាយជាមគ្គុទ្ទេសក៍ទេសចរណ៍ដ៏ចំណាន

## ៤៤-ជំនាញវេជ្ជសាស្ត្រ

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** ជីវវិទ្យា គីមីវិទ្យា និងពលរដ្ឋវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៨ឆ្នាំ ស្មើនឹង ២៧០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋាន ដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងទូទៅផ្នែកវេជ្ជសាស្ត្រ

-យល់ដឹងពីការវិនិច្ឆ័យ និងវិភាគប្រភេទជម្ងឺ និងចេះជ្រើសរើសថ្នាំទៅតាមប្រភេទជម្ងឺ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធ និងបំរើការងារក្នុងសេវាសាធារណៈ និងឯកជន និងបើកជាគ្លីនិកផ្ទាល់ខ្លួន ។

## ៤៥-ជំនាញទន្តពេទ្យសាស្ត្រ

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** ជីវវិទ្យា គីមីវិទ្យា និងពលរដ្ឋវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៧ឆ្នាំ ស្មើនឹង ២៣៤ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋាន ដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងទូទៅផ្នែកទន្តសាស្ត្រ

-ចំណេះដឹងពីតួនាទី និងទីតាំងធ្មេញ និងចេះកំណត់ប្រភេទធ្មេញ

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធ និងបំរើការងារក្នុងសេវាសាធារណៈ និងឯកជន និងបើកជាគ្លីនិកផ្ទាល់ខ្លួន ។

## ៤៦-ជំនាញឱសថសាស្ត្រ

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** ជីវវិទ្យា គីមីវិទ្យា និងពលរដ្ឋវិទ្យា ។

◆ **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៥ឆ្នាំ ស្មើនឹង ១៨០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋាន ដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងទូទៅផ្នែកឱសថសាស្ត្រ

-យល់ដឹងពីការវិភាគអំពីសមាសធាតុផ្សំរបស់ថ្នាំ

-ដឹងពីអន្តរអំពើ និងមេតាបូលីសរបស់ថ្នាំក្នុងសរីរាង្គមនុស្ស

◆ **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធ និងបំរើការងារក្នុងសេវាសាធារណៈ និងឯកជន និងបើកឱសថស្ថានផ្ទាល់ខ្លួន ។

**៤៧.ជំនាញជំនួយវេជ្ជសាស្ត្រ**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះសម្រាប់ទៅសិក្សាលើមុខជំនាញនេះ :** ជីវវិទ្យា គីមីវិទ្យា និងពលរដ្ឋវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៣០ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋាន ដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំ :**

-ចំណេះដឹងទូទៅផ្នែកថែទាំវេជ្ជសាស្ត្រ

-ដឹងពីវិធីសាស្ត្រ និងរបៀបនៃការថែរទាំអ្នកជម្ងឺ

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ក្រសួងសុខាភិបាល ក្រសួងពាក់ព័ន្ធ និងបំរើការងារក្នុងសេវាសាធារណៈ និងឯកជន ។

**៤៨.ជំនាញវិទ្យាសាស្ត្រកសិកម្ម**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ :** គីមីវិទ្យា និងជីវវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរៈពេល ០៤ឆ្នាំ ស្មើនឹង ១៦០ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**

**+ ផ្នែកវិទ្យាសាស្ត្រដី :**

-ដឹងពីប្រភពកំណើរកំណើត និងវិភាគលើលក្ខណៈរូប-គីមីនៃដី

-យល់ដឹងពីការប្រើប្រាស់ដីកសិកម្ម និងប្រព័ន្ធកសិកម្មចំរុះ

-យល់ដឹងពីការប្រើប្រាស់ជីគីមី និងជីធម្មជាតិតាមលក្ខណៈបច្ចេកទេស

**+ផលិតកម្មដំណាំ :**

-យល់ដឹងពីលក្ខណៈជីវសាស្ត្រ និងសារធាតុចិញ្ចឹមរបស់ដំណាំ បច្ចេកទេសដាំដុះ ការរក្សាទុក និងការកែច្នៃផលិតផល

-យល់ដឹងពីបច្ចេកទេសបង្កាត់ពូជ ការផ្សាំ និងការរក្សាគ្រាប់ពូជ

-យល់ដឹងពីការជ្រើសរើសដំណាំតាមស្ថានភាពដី និងអាកាសធាតុ

**+ការការពារដំណាំ :**

-យល់ដឹងពីលក្ខណៈជីវសាស្ត្ររបស់សត្វល្អិត ស្គាល់ពីសត្វមានប្រយោជន៍ និងសត្វបំផ្លាញដំណាំ

-ដឹងពីជម្ងឺរុក្ខជាតិ វិធានការការពារ និងកំចាត់សត្វល្អិតចង្រៃ

-ដឹងពីបច្ចេកទេសប្រើប្រាស់ថ្នាំពុលគីមី និងថ្នាំពុលធម្មជាតិ

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-តាមក្រសួងស្ថាប័នរដ្ឋ ( ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ) អង្គការ និងក្រុមហ៊ុននានា

-អ្នកបណ្តុះបណ្តាលសាស្ត្រាចារ្យតាមវិទ្យាស្ថាន ឬសាកលវិទ្យាល័យ

-អ្នកស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ចូលរួមការងារអភិវឌ្ឍន៍សហគមន៍ និងធ្វើអាជីវកម្មផ្ទាល់ខ្លួន

**៤៩.ជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ**

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះរួមមានៈ** ជីវវិទ្យា និងគីមីវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៦០ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**

**+វិទ្យាសាស្ត្រសត្វ**

-ចេះបង្កាត់ពូជសិប្បនិម្មិត និងបច្ចេកទេសក្នុងការចិញ្ចឹមសត្វ

-យល់ដឹងពីបច្ចេកទេសក្នុងការភ្ញាស់ស៊ុត និងប្រព័ន្ធនៃការចិញ្ចឹម និងផ្តល់ចំណីសត្វចម្រុះ

-យល់ដឹងពីវិធីសាស្ត្រកែច្នៃចំបើងផ្គាប់ធ្វើផ្អកស្មៅ ផ្អកដើមពោត

-យល់ដឹងពីការកែច្នៃកាកសំណល់កសិដ្ឋានរោងចក្រទៅជាជីវឧស្ម័ន សម្រាប់ចំអិនអាហារ បំភ្លឺ និងភ្ញាស់ស៊ុត។

**+ វេជ្ជសាស្ត្រសត្វ**

-ចេះធ្វើរោគវិនិច្ឆ័យ ជម្ងឺឆ្លងសត្វ និងចេះប្រើប្រាស់ឱសថ និងព្យាបាលសត្វ

-យល់ដឹងអំពីជម្ងឺឆ្លង ពីសត្វទៅមនុស្ស ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ស្ថាប័នរដ្ឋ អង្គការ និងតាមស្ថានីយ៍ចិញ្ចឹមសត្វ ក្រុមហ៊ុន ឬកសិដ្ឋានឯកជនផ្ទាល់ខ្លួន

-បើកឱសថស្ថានសត្វឯកជន និងជាអ្នកជំនាញព្យាបាល និងទប់ស្កាត់ជម្ងឺឆ្លងនៅតាមកសិដ្ឋានចិញ្ចឹម ។

## ៥០-ជំនាញវិទ្យាសាស្ត្រព្រៃឈើ

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ រួមមាន :** ជីវវិទ្យា និងគីមីវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង ១៥៨ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**
  - -យល់ដឹងពីការគ្រប់គ្រងធនធានព្រៃឈើ និងតំបន់អេកូទេសចរណ៍
  - -យល់ដឹងពីការថែទាំធនធានធម្មជាតិ បរិស្ថាន និងវាយតម្លៃផលប៉ះពាល់បរិស្ថាន
  - -ដឹងពីការងាររុក្ខវប្បកម្មៈបង្កាត់ពូជឈើ ការគ្រប់គ្រងថ្នាលនិងបណ្តុះកូនឈើ
  - -ដឹងពីការថែទាំព្រៃ រៀបចំតំបន់ប្រភពគ្រាប់ពូជ និងចេះលើកគម្រោងក្នុងវិស័យព្រៃឈើ
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**
  - -ស្ថាប័នរដ្ឋ ( ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ )
  - -វិស័យឯកជន : ក្រុមហ៊ុនព្រៃសម្បទាន ក្រុមហ៊ុនដាំឈើ ក្រុមហ៊ុនកែច្នៃឈើ ក្រុមហ៊ុនរៀបចំតំបន់អេកូទេសចរណ៍ ធម្មជាតិ ។

## ៥១-ជំនាញវិទ្យាសាស្ត្រជលផល

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ :** ជីវៈវិទ្យា និងគីមីវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ១០២ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**
  - -ចំណេះដឹងស្តីពីវារីជីវសាស្ត្រ និងបរិស្ថាន
  - -យល់ដឹងពីការផ្តល់សេវាកម្មបច្ចេកទេស និងផ្សព្វផ្សាយសម្រាប់កសិករ និងសហគ្រិនវារីវប្បកម្ម
  - -ចំណេះដឹងការគ្រប់គ្រងធនធានជលផល ផ្តល់សេវាកម្ម និងផ្សព្វផ្សាយសម្រាប់ការអភិវឌ្ឍន៍ និងការគ្រប់គ្រង សហគមន៍នេសាទ ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**
  - -ស្ថាប័នរដ្ឋ ( រដ្ឋបាលជលផល អង្គការដែលពាក់ព័ន្ធនឹងវិស័យជលផល ក្រសួងបរិស្ថាន)
  - -ភ្នាក់ងារឥណទានកសិកម្ម និងជនបទ សហគ្រាសវារីវប្បកម្មខ្នាតតូច និងមធ្យម ។

## ៥២-ជំនាញបច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម គ្រឿងយន្តកសិកម្ម

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ រួមមាន :** គណិតវិទ្យា និង ភូមិវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ ស្មើនឹង១៥៩ ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**
  - -យល់ដឹងពីវិស្វកម្មប្រព័ន្ធកសិកម្ម (Design សម្ភារៈកសិកម្ម ជួសជុល តម្លើងប្រព័ន្ធអគ្គិសនី និងប្រព័ន្ធត្រជាក់)
  - -យល់ដឹងពីការអភិរក្ស និងគ្រប់គ្រងធនធាន និងដឹងពីការគ្រប់គ្រង ប្រើប្រាស់ និងជួសជុលម៉ាស៊ីនកសិកម្ម ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**
  - -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានគ្រឿងយន្តកសិកម្ម) ក្រសួងធនធានទឹក និងឧតុនិយម
  - -ក្រុមហ៊ុនឯកជន អង្គការក្នុង និងក្រៅរដ្ឋាភិបាល និងអាចបើកអាជីវកម្មផ្ទាល់ខ្លួន ។

## ៥៣-ជំនាញសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ អភិវឌ្ឍន៍សហគមន៍

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ រួមមាន :** គណិតវិទ្យា និងភូមិវិទ្យា ។
- **ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ១២០ ក្រេឌីត ។
- **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**
  - -យល់ដឹងពីគណិតវិទ្យាសេដ្ឋកិច្ច ប្រភេទជំនួញពាណិជ្ជកម្ម និងទីផ្សារកសិកម្ម
  - -យល់ដឹងពីអត្តចរិកអ្នកប្រើប្រាស់ ( អាកប្បកិរិយាអ្នកប្រើប្រាស់) និងទំនាក់ទំនងជំនួញ ។
- **អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**
  - -ស្ថាប័នរដ្ឋ ( ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម )
  - -ស្ថាប័នអង្គការក្រៅរដ្ឋាភិបាល អង្គការ NGO ។

## ៥៤-ជំនាញកសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម

- **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះដើម្បីសិក្សាមុខជំនាញនេះ :** ជីវវិទ្យា និងគីមីវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ឆ្នាំ យ៉ាងតិច ១៥០ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹង ក្រោយពេលបញ្ចប់ការសិក្សារយៈពេល ០៤ ឆ្នាំ :**

-យល់ដឹងពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអាហារ និងបច្ចេកទេសកែច្នៃម្ហូបអាហារនិងផលិតអាហារអង់ស៊ីម

-យល់ដឹងពីបច្ចេកទេសក្រោយពេលប្រមូលផលផលិតផលកសិកម្ម ។

◆**អង្គភាព ឬមូលដ្ឋានដែលអ្នកសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ**

-ស្ថាប័នរដ្ឋ ស្ថាប័នឯកជន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមហ៊ុនផលិតអាហារកញ្ចប់ ។

## ៥៥-ជំនាញរៀបចំដែនដី និងរដ្ឋបាលដីធ្លី

◆**ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះ សម្រាប់ទៅសិក្សាមុខជំនាញនេះគឺ :** គណិតវិទ្យា និងភូមិវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ ស្មើនឹង ១៤៤ ក្រេឌីត ។

◆**ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ឆ្នាំ :**

**+គោលនយោបាយ និងរដ្ឋបាលដីធ្លី**

-ដឹងពីការគ្រប់គ្រងព័ត៌មានដីធ្លី (ការចុះបញ្ជីដីធ្លី ការផ្ទេរ ការជួល និងបញ្ចាំអចលនទ្រព្យ)

-ដឹងពីច្បាប់ដែលពាក់ព័ន្ធនឹងដីធ្លី និងចេះវាយតម្លៃអចលនទ្រព្យ (ពន្ធ និងសម្រាប់ការលក់អចលនទ្រព្យផ្សេង) ។

**+រៀបចំដែនដី**

-ចេះរៀបចំផែនការអភិវឌ្ឍន៍ដីធ្លី និងប្លង់គោលអភិវឌ្ឍន៍ទីក្រុង និងទីប្រជុំជន (Master Plan)

-យល់ដឹងពីការស្រាវជ្រាវ ការបង្កើត និងគ្រប់គ្រងគម្រោង ។

**+ព័ត៌មានភូមិសាស្ត្រ វាស់វែង និងការធ្វើផែនទី**

-យល់ដឹងពីការវាស់វែងដីធ្លី និងការធ្វើផែនទីសុរិយោដី និងបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)

-ដឹងពីរបៀបថត និងបកស្រាយរូបថតពីលើអាកាស ដើម្បីបង្កើតផែនទី និងរៀបចំផែនការអភិវឌ្ឍន៍ផ្សេងៗ ។

◆**អង្គភាព ឬមូលដ្ឋានដែលសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ស្ថាប័នរដ្ឋ : (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក ។ល ។)

-ស្ថាប័នឯកជន (ធនាគារ ក្រុមហ៊ុនអចលនទ្រព្យ លក់ឧបករណ៍ GPS សំណង់ វាស់វែង សម្បទានដីធ្លី ។ល ។)

-អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ

## ៥៦-ជំនាញគ្រប់គ្រងធនធានធម្មជាតិ

◆ **ចំណេះដឹងមូលដ្ឋានដែលបេក្ខជនត្រូវចេះ សម្រាប់ទៅសិក្សាមុខជំនាញនេះគឺ :** គីមីវិទ្យា និងជីវវិទ្យា ។

◆**ការសិក្សាដើម្បីទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រលើមុខជំនាញនេះ :** មានរយៈពេល ០៤ ឆ្នាំ យ៉ាងតិច ១២០ ក្រេឌីត ។

◆ **ចំណេះដឹងមូលដ្ឋានដែលនិស្សិតបានយល់ដឹងក្រោយពេលបញ្ចប់ការសិក្សារយៈពេល ៤ឆ្នាំ :**

-ចំណេះដឹងទូទៅនៃការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងទឹក និងការប្រើប្រាស់ជីវុក្ខកម្ម

-យល់ដឹងពីការគ្រប់គ្រងធនធានព្រៃឈើ ជីវសាស្ត្រចម្រុះ កាកសំណល់ និងការគ្រប់គ្រងធនធានតំបន់ឆ្នេរ ។

◆**អង្គភាព ឬមូលដ្ឋានដែលសិក្សាចប់មុខជំនាញនេះ អាចទៅបម្រើការងារ :**

-ស្ថាប័នរដ្ឋ (ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ)

-អង្គការជាតិ និងអន្តរជាតិ ដែលទាក់ទងទៅនឹងការថែរក្សាធនធានធម្មជាតិ (ជលផល ព្រៃឈើ សត្វព្រៃ)